ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា**
**ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ**
លេខៈ......០៤២/១៧.......គ.ផ.ថ/ល.ក.ព

# សេចក្តីជូនដំណឹង
# ស្តីពីការកែសម្រួលនីតិវិធីនៃការបញ្ជាក់អត្តសញ្ញាណ
# ជូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ

ដើម្បីសម្រួលដល់បងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានកែសម្រួល និងកំណត់នីតិវិធីដូចខាងក្រោម៖

I. ការផលិតលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) **និងឯកសារតម្រូវនានា៖**

១. ការផលិត និងបើកផ្តល់ លិខិតធ្វើដំណើរ(TD) និងប័ណ្ណ(OCWC) ជូនពលករ គឺធ្វើឡើងក្នុងថ្ងៃតែមួយ

២. ពលករត្រូវផ្តល់ឯកសារ ដូចខាងក្រោម៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ សំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ ឬ លិខិតឆ្លងដែន ឬ ប័ណ្ណបើកបរ **ច្បាប់ថតចម្លង ចំនួន ២ច្បាប់**
- ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណពណ៌ស៊ីជម្ពូ) ឬ លិខិតបញ្ជាក់ទំនាក់ទំនងរវាងនិយោជក និងពលករ ចេញដោយក្រសួងការងារថៃ ឬ មន្ទីរការងារថៃ **ច្បាប់ថតចម្លង ចំនួន២ច្បាប់។**

៣. ពលករត្រូវមកដោយផ្ទាល់ និងថតរូបដោយផ្ទាល់ ព្រមទាំងត្រូវផ្តល់ព័ត៌មានដូចខាងក្រោម៖

- ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់និយោជក នៅប្រទេសថៃ
- ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់អ្នកត្រូវទទួលសំណងធានារ៉ាប់រង នៅពេលមានគ្រោះថ្នាក់។

**II. ទីកន្លែង ថ្ងៃម៉ោងធ្វើការ និងតម្លៃសេវា**

១.ទីកន្លែង ៖

- ទីក្រុងបាងកក ៖ អាសយដ្ឋាន អ៊ីមផើរៀល(Imperial World Ladphrao)ឡាតប្រាវ ជាន់

ទី៤, លេខ២៥៣៩, ច្រក៨១-៨៣ ផ្លូវឡាតប្រាវ, សង្កាត់ ចៅឃុនស៊ីង, ខណ្ឌ ចុងឡាង, ទីក្រុងបាងកក ១០៣១០

- ខេត្តរ៉ាក់យ៉ង ៖ អាសយដ្ឋាន ផ្សារ អូថប់ម៉ាយ៉ង(OTOP MA YONG) -២០១ ភូមិ ៧, ឃុំ ម៉ាខាមឃូ, ស្រុក និឃុំផាត់តាណា, ខេត្ត រ៉ាក់យ៉ង២១១៨០
- ខេត្តសុងក្លា ៖ អាសយដ្ឋាន ផ្សារ ហ្វុកទៀន(Fuk Thian), ៩៩ភូមិ៣, ឃុំ ខ្លងហែរ, ស្រុក ហ៉ាត់យៃ, ខេត្ត សុងក្លា

២.ថ្ងៃម៉ោងធ្វើការ ៖ ថ្ងៃច័ន្ទ ដល់ ថ្ងៃសៅរ៍

- បាងកក ៖ ព្រឹកម៉ោង ១០:០០ ដល់ ៦:៣០ ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៥:០០ ល្ងាច
- ខេត្តរ៉ាក់យ៉ង ៖ ព្រឹកម៉ោង ៨:៣០ ដល់ ៥:៣០ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៣:៣០ ល្ងាច
- ខេត្តសុងក្លា ៖ ព្រឹកម៉ោង ៨:៣០ ដល់ ៥:៣០ ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៣:៣០ ល្ងាច

៣.តម្លៃសេវាផ្លូវការក្នុងការធ្វើ និងបើកផ្តល់សំណុំឯកសារក្នុងថ្ងៃតែមួយដែលភាគីថៃ និងកម្ពុជាបានឯកភាពគ្នាគឺ ២ ៣៥០ (ពីរពាន់បីរយហាសិប)បាត។

**III. អ្នកក្នុងបន្ទុករបស់ពលករអាយុក្រោម ១៥ឆ្នាំ មិនយកកម្រៃសេវា**

១. ត្រូវនាំកូន ឬអ្នកក្នុងបន្ទុកមកដោយផ្ទាល់ និងថតរូបដោយផ្ទាល់

២. សំបុត្រពេទ្យ ឬ សំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសបងប្អូនពលករកម្ពុជាអនុវត្តទៅតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីនិងជាប្រធានគណៈកម្មការ**

**អ៊ិត សំហេង**